TUKTUK

# សួស្តីឆ្នាំថ្មី

## HAPPY KHMER NEW YEAR



និពន្ធដោយ TukTuk

រូបភាពដោយ Hen Choven



ថ្ងៃនេះ រតនានិងមករាសប្បាយចិត្តខ្លាំងណាស់
ដោយសាររ៉ាកងតូចទើបចាប់ផ្ដើម។



ថ្ងៃចូលឆ្នាំប្រពៃណីខ្មែរជិតមកដល់ហើយ ដូចនេះម្នាក់ៗរវល់ណាស់
ព្រោះមានរបស់របរច្រើនត្រូវរៀបចំ។



នៅថ្ងៃចន្ទ រតនានិងមករាបានទៅទិញខោអាវនៅផ្សារជាមួយម្តាយគាត់។

រតនាស្រឡាញ់រ៉ូបពណ៌ខៀវដ៏ស្រស់ស្អាតមួយ តែពេលនាងលទៅ រ៉ូបនោះបែរជាតូចពេក។



ដូច្នេះនាងក៏សាកលរ៉ូបពណ៌បៃតងវិញ តែវាបែរជាធំពេកទៅវិញ។
ចុងក្រោយនាងក៏សាករ៉ូបពណ៌លឿងមួយដែលត្រូវនឹងខ្លួននាងល្មមតែម្តង។




ឯមករាវិញបានទិញខោពណ៌ក្រហមនិងអាវយឺតឆ្នូតមួយផងដែរ។




នៅថ្ងៃអង្គារ មានសំឡេងស៊ីប្លេនៅក្រៅផ្ទះរបស់ក្មេងៗ។
ម្ដាយរបស់ក្មេងទាំងពីរនិយាយ « ម៉ោះ! ថ្ងៃនេះយើងត្រូវទិញអីវ៉ាន់ច្រើនណាស់ »។




លោកគ្រូសុខកំពុងចាំពួកគេនៅលើរ៉ឺម៉កកង់បី។

សាកទាយមើលនរណាគេជាអ្នកបើករ៉ឺម៉កកង់បី? គឺយ៉េកនោះឯង!




រតនានិងមករាសប្បាយចិត្តណាស់ដែលបានជួបយ៉េកម្តងទៀត។
លោកគ្រូសុខបានណែនាំយ៉េកឱ្យម្តាយក្មេងទាំងពីរបានស្គាល់។




រតនាសួរ « តើខេទីនៅឯណា? »
យ៉េកក៏ឆ្លើយ « មកពីមនុស្សច្រើនពេក ប្រហែលជិះមិនអស់ទេ ដូច្នេះនាងក៏ចាំនៅផ្ទះទៅ »។





ពេលទៅដល់ផ្សារ ពួកគេបានទិញភ្លើងលំអ ទាននិងធូបជាច្រើន។
យ៉េកសួរ « ទិញរបស់ទាំងនេះសម្រាប់ធ្វើអីហ្នឹង? »









មកាឆ្លើយ « សម្រាប់អបអរថ្ងៃចូលឆ្នាំខ្មែរហ្នឹងណា »។
« ចុះស្បោងធំនោះវិញដាក់អីហ្នឹង? » តែលោកគ្រូសុខមិនឆ្លើយទេ បានត្រឹមញញឹម។






ម្ដាយពួកគេក៏សួរទៅយ៉េក « យ៉េក! ចុះថ្ងៃបុណ្យចូលឆ្នាំខ្មែរនេះប្រុងធ្វើអ្វីដែរ? »
យ៉េកឆ្លើយ « អត់មានគម្រោងថានឹងធ្វើអីផង »។









ម្ដាយពួកគេនិយាយទៀត « អីចឹងអ្នកនិងខេទីអាចមកលេងពួកយើងបាន
ហើយសឹមទៅវត្តទាំងអស់គ្នាតែម្ដង »។









យ៉េកក៏ឆ្លើយ « បើអ៊ីចឹងមែនប្រសើរណាស់! អរគុណមីងច្រើនមែនទែន។ ចាំខ្ញុំដឹកអ្នកទាំងអស់គ្នាទៅតែម្តង »។






ឮដូចនេះ ក្មេងៗក៏ស្រែកហ៊ោដោយក្តីសប្បាយរីករាយ។



នៅថ្ងៃពុធ រតនានិងមករាជួយម្ដាយពួកគេសម្អាតផ្ទះ ខណៈពេលដែលគាត់នៅរវល់រៀបចំចម្អិនចំណីអាហារ។



រីឯថ្ងៃព្រហស្បតិ៍ញ យ៉េកនិងខេទីបានជិះរ៉ឺម៉កកង់បីមកដឹកអ្នកទាំងអស់គ្នា
ទៅផ្សារម្តងទៀត។



ម្តងនេះ ពួកគាត់ទិញតែផ្លែឈើប៉ុណ្ណោះ មានផ្លែម្នាស់ ក្រូច ស្វាយ ល្ហុង ចេកនិងផ្លែខ្នុរ។ យប់នោះ រតនានិងមករាសប្បាយចិត្តខ្លាំងសឹងតែដេកមិនលក់។



ជាចុងក្រោយ ថ្ងៃសុក្រដែលជាថ្ងៃចូលឆ្នាំទីមួយបានមកដល់។ យ៉េកនិងខេទីនាំគ្នាជិះរ៉ឺម៉កកង់បីមកជាមួយគ្នា ឯលោកគ្រូសុខបានដើរមកជួបជុំគ្នានៅផ្ទះរតនានិងមករា។



ខេទីលាន់មាត់ « អូ! តុបតែងបានស្អាតខ្លាំងណាស់ថ្ងៃនេះ »។

លោកគ្រូសុខក៏ប្រាប់យ៉េកនិងខេទី ថាថ្ងៃទីមួយនៃបុណ្យចូលឆ្នាំខ្មែរគេហៅថា ថ្ងៃមហាសង្រ្កាន្ត។



« នេះជាថ្ងៃដែលយើងទទួលស្វាគមន៍ទេវតាឆ្នាំថ្មី។ ផ្លែឈើ ទានធូបនិងភ្លើងលំអទាំងនេះ
ជារណ្ដាប់សម្រាប់ទទួលទេវតាឆ្នាំថ្មី ដើម្បីឱ្យទ្រង់ប្រោសប្រណីការពារផ្ទះនិងក្រុមគ្រួសារយើង។



បន្ទាប់មក យើងនឹងទៅវត្តដើម្បីប្រគេនចង្ហាន់ជូនលោកសង្ឃផងដែរ »។



នៅលើរ៉ឺម៉កកង់បី មករាបានសួរខេទី « តើអ្នកចេះសំពះថ្វាយបង្គំលោកសង្ឃឬទេ? »
ខេទីប្រាប់ « ខ្ញុំមិនចេះទេ »។



មករាក៏ដាក់ដៃផ្ទឹមគ្នា ហើយលើកដៃសំពះដល់ថ្ងាសឱនចុះឱនឡើងចំនួនបីដង។
គាត់ប្រាប់ខេទី « នេះហើយជារបៀបសំពះលោកសង្ឃ។ ខ្ញុំទើបរៀនចេះពីសាលាមត្តេយ្យមក! »



ថ្ងៃបន្ទាប់ជាថ្ងៃសៅរ៍ យ៉េកក៏បានមកដឹកអ្នកទាំងអស់គ្នាទៅវត្តម្តងទៀត។
ខេទីសួរលោកគ្រូសុខ « ថ្ងៃនេះជាថ្ងៃអ្វី? »



« នេះជាថ្ងៃទីពីរនៃពិធីបុណ្យចូលឆ្នាំដែលឈ្មោះថា វារៈវ័នបត។



ថ្ងៃនេះជាថ្ងៃដែលយើងរំលឹកដល់ដូនតាយើងដោយប្រគេនចង្ហាន់ដល់លោកសង្ឃ
និងឱ្យទានដល់អ្នកក្រខ្សត់ »។



ក្រោយពីបានប្រគេនចង្ហាន់លោករួចរាល់ហើយ រតនានិងមករាបានទៅអង្គុយកាយខ្សាច់។



ខេទីឆ្វល់ក៏សួរ « តើអ្នកទាំងពីរកំពុងលេងដីមែនហ្នឹង? »

មករាឆ្លើយវិញ « មិនមែនទេ! យើងកំពុងពូនខ្សាច់ដើម្បីដាក់លើវាលុកចេតិយជាភ្នំខ្សាច់នៅទីនេះ។



ដំបូង យើងពូនចេតិយនៅកណ្ដាល ហើយបន្តពូនលើគ្រប់ចេតិយទាំងអស់ពីឆ្វេងទៅស្ដាំ។
យើងធ្វើអ៊ីចឹងគឺដើម្បីបួងសួងដល់ដូនតាយើងនិងសុំឱ្យគ្រួសារយើងមានសុខភាពល្អផងដែរ »។



ថ្ងៃអាទិត្យជាថ្ងៃចុងក្រោយនៃពិធីបុណ្យចូលឆ្នាំដែលមានឈ្មោះថា វារៈឡើងស័ក។ នៅវត្ត គេនាំគ្នាយកទឹកទៅស្រង់ព្រះ។



រតនាប្រាប់ខេទី « ធ្វើអ៊ីចឹងគឺយើងលាងបាបដែលយើងបានសាងពីឆ្នាំមុន
ហើយវាក៏នាំសេចក្ដីសុខមកឱ្យយើងនៅឆ្នាំថ្មីនេះផងដែរ »។



ពេលទៅដល់ភូមិវិញ ដល់ពេលគេនាំគ្នាស្រង់ព្រះរស់ម្តង។
រតនានិងមករាក៏បានចូលជួយគេស្រង់ព្រះរស់នឹងគេផងដែរ។



រតនានិយាយ « ខ្ញុំសង្ឃឹមថាលោកតានឹងឱ្យដំបូន្មានល្អៗដល់ខ្ញុំដូចឆ្នាំមុនៗអីចឹង »។



ក្រោយពេលគេបានស្រង់ព្រះរស់រួចរាល់អស់ហើយនោះ ពួកគេក៏ញ៉ាំបាយជុំគ្នា។
ក្រោយពីញ៉ាំចប់សព្វគ្រប់ហើយនោះ លោកគ្រូសុខក៏បានដើរលបៗទៅក្រោយបាត់...



« តើទាំងអស់គ្នារៀបចំខ្លួនហើយឬនៅ? »

លោកគ្រូសុខនិយាយទាំងដៃមានកាន់ស្បោងខៀវធំមួយ។



« យ៉េ! » ពួកក្មេងៗស្រែកហើយរត់ជុំវិញលោកគ្រូសុខ។
មករាស្រែកប្រាប់ឱ្យយ៉េកចូលទៅខាងប្រុស។ រតនាក៏ប្រាប់ឱ្យខេទីចូលជួយខាងស្រី។



យ៉េកឆ្វល់ក៏សួរ « គេកំពុងធ្វើអីហ្នឹង? »
លោកគ្រូសុខក៏ឆ្លើយ « ដល់ពេលលេងល្បែងប្រជាប្រិយខ្មែរយើងហើយ! »



ដំបូង ពួកគាត់លេងល្បែងចោលឈូង



បោះអង្គុញ



និងស្វាដណ្ដើមស្លឹកឈើសិន។

ក្រុមខាងស្រីស្រែកហ៊ោកញ្ជៀវ ដោយសារក្រុមខាងប្រុសៗចាញ់ ហើយត្រូវច្រៀងនិងរាំជាពិន័យ។



បន្ទាប់មកលោកគ្រូសុខបានប្រាប់ទាំងអស់គ្នាឱ្យអង្គុយជារង្វង់។
ម្នាក់ៗក៏ធ្វើតាមសំដីគាត់ ហើយពួកគេក៏ចាប់ផ្ដើមលេងល្បែងលាក់កន្សែង។



ក្មេងៗចូលចិត្តដេញចាប់យ៉េកនិងខេទីណាស់។




« បាទ! ដល់ពេលយើងលេងទាញព្រ័ត្រហើយ! »
« យ៉េ! » ម្នាក់ៗហក់ឡើងឈរ ហើយតម្រង់ជួរ។




« ១ ២ ៣ ចាប់ផ្ដើម! » យ៉េកក៏ចូលជួរជាមួយក្រុមប្រុសៗ។



តែភ្លាមនោះ ក្រុមខាងស្រីៗក៏នាំគ្នាស្រែកថា « អយុត្តិធម៌ណាស់!
យ៉េកមានកម្លាំងស្មើមនុស្សដប់នាក់ទៅហើយហ្នឹង! »



លោកគ្រូសុខក៏ដោះស្រាយ « មិនអីទេៗ!
ម្ដងនេះ ពីរនាក់ខ្ញុំនិងយ៉េកនឹងទាញជាមួយអ្នកទាំងអស់គ្នាក៏បាន »។



« យេ៎! » ក្មេងៗនាំគ្នាស្រែកសប្បាយរីករាយ។




យ៉េកក៏លាន់មាត់ « ពិធីបុណ្យចូលឆ្នាំខ្មែរពិតជាសប្បាយពិតមែន!
រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មីទាំងអស់គ្នា! »។




ក្មេងៗក៏ស្រែកតប « រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មី! »។
ខេទីក៏ស្រែកសួរពីក្រោយ « រៀបចំខ្លួនហើយឬនៅទាំងអស់គ្នា? ១ ២ ៣ ចាប់ផ្ដើម! »៕

ចប់ដោយបរិបូរណ៍

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(**R4C**)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការ**R4C**កំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ**R4C**បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួងនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រ ដើម្បីទទួលបានធនធានបង្រៀន៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

មូលនិធិផ្តល់ដោយអង្គការ**TukTuk** និងសមាគមរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ **Robert McCurdy** និង**Roberta Dahl** ជាអ្នកស្ម័គ្រចិត្តដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង**Sally Heinrich** ដែលបានចូលរួមកែសម្រួលនិងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន